

# បច្ចុប្បន្នភាពទីផ្សារ និង ការតាមដានរដូវកាល

ខែកុម្ភៈ ឆ្នាំ២០២៣

## ប្រទេសកម្ពុជា

### ផ្តោតលើ៖ ឥទ្ធិពលនៃវិបត្តិស្បៀងអាហារ និងប្រេងឥន្ធនៈសកលលោក លើតម្លៃស្បៀងអាហារ និងដំណើរការរបស់ផ្សារ

កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ សហការជាមួយ
ការិយាល័យទីផ្សារកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ


**ការិយាល័យទីផ្សារកសិកម្ម (AMO)**
នាយកដ្ឋានផែនការនឹងស្ថិតិ,
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មៀច យ៉ាឌី meachyady@gmail.com
គេហទំព័រ: https://amis.maff.gov.kh/

**កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ**
ផ្នែកវិភាគ និងធ្វើផែនទីភាពងាយរងគ្រោះនៅក្នុងការិយាល័យប្រចាំប្រទេសកម្ពុជា
Benjamin Scholz benjamin.scholz@wfp.org, ឡុង យ៉ាវ yav.long@wfp.org , ជឿ ច័ន្ទវិបុល chanvibol.choeur@wfp.org,
ហួយ វណ្ណារ៉េត vannareth.huoy@wfp.org, Akshaya Devasia akshaya.devasia@wfp.org
គេហទំព័រ៖ https://www.wfp.org/countries/cambodia

# បុព្វកថា

**រយៈពេលច្រើនជាង១ឆ្នាំនៃជម្លោះអ៊ុយក្រែន** សង្គ្រាម និងការដាក់ទណ្ឌកម្មលើរុស្ស៊ី នៅតែធ្វើឱ្យប៉ះពាល់ខ្លាំងដល់ទីផ្សារថាមពល និងស្បៀងអាហារ ដោយសារប្រទេសទាំងពីរជាអ្នកនាំចេញគ្រាប់ធញ្ញជាតិសំខាន់ (ជាពិសេសស្រូវសាឡី និងស្រូវបាឡេ) ជីកសិកម្ម (ដូចជាប៉ូតាស្យូម អាសូត ផូស្វ័រ) ហើយរុស្ស៊ី គឺជាប្រទេសដែលផលិត និងនាំចេញប្រេងឆៅ និងឧស្ម័នធម្មជាតិដ៏ធំរបស់ពិភពលោក។ ខណៈដែលធាតុអាកាសអំណោយផល និងការឆ្លើយតបផ្នែកផ្គត់ផ្គង់ដ៏រឹងមាំបានកាត់បន្ថយការកើនឡើងតម្លៃក្នុងឆ្នាំ២០២៣ ការផ្គត់ផ្គង់ដ៏តឹងតែងបង្ហាញពីភាពប្រែប្រួលកាន់តែខ្លាំង ជាពិសេសកំឡុងពេលដែលមិនអាចទាយទុកជាមុនបាន ឧ. ពេលវេលាដាំដុះនៅអឌ្ឍគោលខាងជើង។

សន្ទស្សន៍តម្លៃស្បៀងអាហារសកលរបស់ FAO ក្នុងខែកុម្ភៈ ឆ្នាំ២០២៣ បន្តថយចុះ បន្ទាប់ពីបានឡើងខ្ពស់បំផុតក្នុងខែមីនា ឆ្នាំ២០២២។ វាទាបជាងខែមុន ០,៦% និង ខែដដែលកាលពីឆ្នាំមុន ៨,១% ដោយសារការធ្លាក់ចុះតម្លៃប្រេងឆា និងផលិតផលទឹកដោះគោ។

កំណើនសេដ្ឋកិច្ចសកលបានព្យាករថា ២,៩% ក្នុងឆ្នាំ២០២៣ និង ៣,១% ក្នុងឆ្នាំ២០២៤ ដែលទាបជាងមធ្យមភាគមុនការរាតត្បាតជំងឺកូវីដ-១៩។ អតិផរណាសកលបានព្យាករថានឹងថយចុះ ៦,៦% ក្នុងឆ្នាំ២០២៣ និង ៤,៣% ក្នុងឆ្នាំ២០២៤ ដែលនៅតែខ្ពស់ជាងមុនការរាតត្បាតជំងឺកូវីដ-១៩។ ការធ្លាក់ចុះសេដ្ឋកិច្ចទំនងជានឹងធ្វើឱ្យតម្រូវការថយចុះ ជាហេតុធ្វើឱ្យតម្លៃស្បៀងអាហារថយចុះ (ឧ. ថាមពល កសិកម្ម និងលោហៈ) ក្នុងឆ្នាំ២០២៣ និង២០២៤ ប៉ុន្តែនៅតែខ្ពស់ជាងប្រវត្តិតម្លៃ ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ។ នេះទំនងជាធ្វើឱ្យវិបត្តិតម្លៃនៃការរស់នៅ ក្លាយជាហានិភ័យសកលដ៏ធ្ងន់ធ្ងរជាងគេក្នុងរយៈពេលពីរឆ្នាំខាងមុខ។

**លទ្ធភាពទទួលបានជីកសិកម្មមានភាពប្រសើរឡើងវិញ** ដោយសារតែតម្លៃជីបានថយចុះ ៤០% ធៀបនឹងដើមឆ្នាំ២០២២ជាពេលដែលតម្លៃឡើងខ្ពស់បំផុត តែនៅខ្ពស់ជាងមធ្យមភាគច្រើនឆ្នាំ។ នេះទំនងជាធ្វើឱ្យតម្លៃធាតុចូលកសិកម្មមានការថយចុះ និងផលិតកម្មស្បៀងអាហារសកលមានភាពប្រសើរឡើង។ តម្លៃផលិតកម្មកសិកម្មសកលរំពឹងទុកថានឹងថយចុះ ៥,០% ក្នុងឆ្នាំ២០២៣ ប៉ុន្តែវានៅតែខ្ពស់ជាងពីមុន។ ការប្រែប្រួលអាកាសធាតុ និងភាពមិនច្បាស់លាស់នៃសង្គ្រាមរុស្ស៊ី និងអ៊ុយក្រែនធ្វើឱ្យមានហានិភ័យនៃវិបត្តិតម្លៃស្បៀងអាហារសកល។

**វិបត្តិស្បៀងអាហារពិភពលោក ត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរមួយផ្នែក ដោយការរឹតបន្តឹងពាណិជ្ជកម្មស្បៀងអាហារ**ដែលដាក់ដោយប្រទេសមួយចំនួនដើម្បីបង្កើនការផ្គត់ផ្គង់ក្នុងស្រុក និងកាត់បន្ថយតម្លៃ។ គិតត្រឹមថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ប្រទេសចំនួន ២៣ បានជំរុញឱ្យមានការហាមឃាត់ការនាំចេញអាហារ ចំនួន ២៨ ហើយប្រទេសចំនួន ៦ បានអនុវត្តវិធានការកំណត់ការនាំចេញចំនួន ៥។ ធនាគារពិភពលោកព្រមានថ ការរិតត្បិតថ្មីលើការនាំចេញអាច'ធ្វើ ឱ្យតម្លៃកើនឡើងម្តងទៀត'។

**បញ្ហានេះមិនបានកើតឡើងដាច់ដោយឡែកនោះទេ។** កូវីដ-១៩ បានប៉ះពាល់ជាអវិជ្ជមានដល់ប្រាក់ចំណូល និងតម្រូវការគ្រួសារ ជាហេតុធ្វើឱ្យមានឧបសគ្គដល់ខ្សែច្រវ៉ាក់ផ្គត់ផ្គង់សកល កើនឡើងអតិផរណា និងបំណុលក្នុងប្រទេសជាច្រើន - ធ្វើឱ្យរំខានដល់ការស្តារសេដ្ឋកិច្ចពីការរាតត្បាតកូវីដ-១៩។ ភស្តុតាងចង្អុលបង្ហាញពីស្ថានភាពសន្តិសុខស្បៀងដែលមិនស្ថិតស្ថេរ ក្នុងចំណោមគ្រួសារកម្ពុជា ជាពិសេសសម្រាប់អ្នកដែលងាយរងគ្រោះបំផុត និងអ្នករស់នៅក្នុងតំបន់ងាយរងគ្រោះដោយទឹកជំនន់។

**ដើម្បីស្វែងយល់ពីឥទ្ធិពលនៃបញ្ហាទាំងនេះ:** លើភាពមានស្បៀង និងលទ្ធភាពទទួលបានស្បៀងនៅតាមផ្សារនានាក្នុងប្រទេសកម្ពុជា កម្មវិធីស្បៀងអាហារពិភពលោក (WFP) សហការជាមួយការិយាល័យទីផ្សារកសិកម្ម (AMO) តាមដានតម្លៃលក់រាយ និងលក់ដុំ របស់ស្បៀងអាហារសំខាន់ៗ នៅក្នុងផ្សារចំនួន៥៦ ទាំងនៅទីប្រជុំជន និងជនបទទូទាំងប្រទេស (សូមមើលផ្នែកវិធីសាស្ត្រ)។ ប្រធានផ្សារក៏ត្រូវបានសម្ភាសន៍ផងដែរ ដើម្បីវាយតម្លៃពីដំណើរការរបស់ទីផ្សារ ទាំងបញ្ហាផ្គត់ផ្គង់ស្បៀង និងតម្រូវការស្បៀង។ ជាមធ្យម ប្រធានផ្សារ និងអាជីវករ ចំនួន ១.០០០ នាក់ត្រូវបានសម្ភាសន៍ជារៀងរាល់ពីរសប្តាហ៍។

# មាតិកា


១. **របកគំហើញសំខាន់ៗ** ៣

២. **លទ្ធផល**

ការដំណើរការរបស់ផ្សារ៖ ទិដ្ឋភាពទូទៅ ៤

ការទៅផ្សារ៖ទិន្នាការអតិថិជន ៥

ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ៦

ថ្នាក់ក្រោមជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ៧

ថ្នាក់ជាតិ៖ ប្រាក់ឈ្នួលពលកម្ម និងកម្លាំងទិញស្បៀងអាហារ ៨

ថ្នាក់ជាតិ៖ និន្នាការតម្លៃអង្ករចម្រុះ ស៊ុតទា និងត្រកួន ៩

ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា ១០

ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ និងទីប្រជុំជន ១១

ការតាមដានរដូវកាល៖ របាយទឹកភ្លៀង ១២

ការតាមដានរដូវកាល៖ ស្ថានភាពរុក្ខជាតិ និងដំណាំ ១៣

៣. **បរិបទ**

ពាណិជ្ជកម្ម ១៤

ការឆ្លើយតបផ្នែកនយោបាយ ១៥

៤. **វិធីសាស្ត្រ និងទីតាំងផ្សារ** ១៦

៥. **ឧបសម្ព័ន្ធទី១**

បម្រែបម្រួលថ្លៃលក់រាយ ១៧

៦. **ឧបសម្ព័ន្ធទី២**

បម្រែបម្រួលថ្លៃលក់ដុំ ១៨

៧. **ឧបសម្ព័ន្ធទី៣**

តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ១៩

## កត្តាបរិស្ថានដែលមានឥទ្ធិពលលើតម្លៃ

**កំណើនសេដ្ឋកិច្ច**

២០២២ ៥,២%

២០២៣ ៥,៦%*

**អតិផរណា**

CPI ធ្នូ ២០២២ ១៩៧,៥

CPI មករា ២០២៣ ១៩៨,៨

*ផលិតផលក្នុងស្រុកសរុប (GDP) របស់កម្ពុជាក្នុងឆ្នាំ២០២២គឺ ៥,២% ហើយព្យាករថានឹងកើន ៥,៦% ក្នុងឆ្នាំ២០២៣*។ ក្នុងខែមករា ឆ្នាំ២០២៣ សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់រួម** (CPI) បានកើនឡើង ០,៧% ធៀបនឹងខែមុន និង៣,០% ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន។ អតិផរណាស្បៀងអាហារក្នុងស្រុកមានភាពប្រសើរឡើងវិញមកដល់ចុងខែធ្នូ ឆ្នាំ២០២២។ គ្រួសារកម្ពុជាចំណាយស្ទើរតែពាក់កណ្ដាល (៤៨,៧%) នៃប្រាក់ចំណូលរបស់ខ្លួនលើស្បៀងអាហារ។ គ្រួសារក្រីក្រចំណាយ ៥៦% (CSES ២០១៩/២០)។*

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF)*
*** CPI ក្នុងខែកុម្ភៈ ឆ្នាំ២០២៣ មិនទាន់មាននៅឡើយទេ កំឡុងពេលរៀបចំរបាយការណ៍*




*ក្នុងខែកុម្ភៈ ឆ្នាំ២០២៣ **[សន្ទស្សន៍តម្លៃស្បៀងអាហារសកលរបស់ FAO(FFPI)](#) បានធ្លាក់ដល់** ១២៩,៨ (-០,៦% ធៀបនឹងខែមុន និង -៨,១% ធៀបនឹងខែដូចគ្នាក្នុងឆ្នាំមុន)។ **សន្ទស្សន៍តម្លៃស្បៀងអាហារកម្ពុជា (FPI)** ជាផ្នែកមួយនៃ CPI របស់កម្ពុជា បានកើនឡើង ០,៤% ធៀបនឹងខែធ្នូ ឆ្នាំ២០២៣ ៣,៧% ធៀបនឹងខែដដែលកាលពីឆ្នាំមុន។*

មករា កុម្ភៈ មីនា មេសា ឧសភា មិថុនា កក្កដា សីហា កញ្ញា តុលា វិច្ឆិកា ធ្នូ




***[តម្លៃប្រេងឥន្ធនៈនៅកម្ពុជា](#)មានការប្រែប្រួលតិចតួច (±៥%) ក្នុងខែកុម្ភៈ ឆ្នាំ២០២៣ (MOC, ២០២៣)។*** *តម្លៃលក់រាយប្រេងសាំង (ធម្មតា) បានកើនឡើង ៣,៥% តែទាបជាងតម្លៃកាលពីឆ្នាំមុន (-៤,០%)។ តម្លៃប្រេងម៉ាស៊ូតបានថយចុះ -១,៨% បើធៀបនឹងខែមុន ប៉ុន្តែខ្ពស់ជាងខែដដែលកាលពីឆ្នាំមុនបន្តិច (+១,៩%) ហើយ**ប្រហែលនៅតែមានឥទ្ធិពលអវិជ្ជមានលើផលិតកម្ម និងតម្លៃស្បៀង**។*

មករា កុម្ភៈ មីនា មេសា ឧសភា មិថុនា កក្កដា សីហា កញ្ញា តុលា វិច្ឆិកា ធ្នូ

# សង្ខេបរបកគំហើញសំខាន់ៗ

នៅក្នុងខែកុម្ភៈ ឆ្នាំ២០២៣ កញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របស់ WFP មានតម្លៃ ២៦,២ ដុល្លារ គឺកើនឡើងបន្តិច (+១,១%) បើប្រៀបធៀបទៅនឹងខែមុន (MoM)។ ហើយវានៅតែមានតម្លៃថ្លៃជាង (+៦,៦%) រយៈពេលដូចគ្នាកាលពីឆ្នាំមុន (YoY)។ នៅជនបទ BFB មានតម្លៃ ២៥,៥ ដុល្លារ (+១,៤% ធៀបនឹងខែមុន) ហើយនៅទីប្រជុំជន BFB មានតម្លៃ ២៦,៦ ដុល្លារ (+០,៤% ធៀបនឹងខែមុន)។

នៅក្នុងខែកុម្ភៈ ឆ្នាំ២០២៣ តម្លៃស្បៀងអាហារនៅក្នុងកញ្ចប់មានបម្រែបម្រួលតិចតួច (±<៥,០% ធៀបនឹងខែមុន)។ ភាពប្រសើរឡើងនៃតម្លៃស្បៀងអាចជាប់ទាក់ទងទៅនឹងការធ្លាក់ចុះនៃតម្លៃប្រេងឥន្ធនៈ និងធាតុចូលកសិកម្ម។ ប៉ុន្តែតម្លៃស្បៀងអាហារមួយចំនួននៅតែបង្ហាញនិន្នាការកើនឡើងក្នុងរយៈពេលវែង ដូចជា ស្រីផ្ទក់ (+១៨,៨% YoY) ស៊ុតទា (+១២,៩% YoY) ត្រកួន (+២៧,២% YoY) និងដំឡូងជ្វា (+៣២,៦% YoY) ដែលនៅតែមានតម្លៃខ្ពស់គួរឱ្យកត់សម្គាល់។

គិតត្រឹមខែកុម្ភៈ ឆ្នាំ២០២៣ ការបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចលើសពីផែនការថ្នាក់ជាតិ ដោយសារតែអំណោយផលនៃស្ថានភាពភ្លៀងធ្លាក់ និងទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រប ស្របពេលដែលមានភាពប្រសើរឡើងនូវតម្លៃប្រេងម៉ាស៊ូត ដែលជាប្រភពថាមពលដ៏សំខាន់ចំពោះផលិតកម្មកសិកម្ម។

ដំណើរការរបស់ផ្សារបានធ្លាក់ចុះបន្តិចក្នុងខែកុម្ភៈ ដោយសារភាពខ្វះខាតនៃទំនិញចាំបាច់ក្នុងបរិមាណគ្រប់គ្រាន់ និងភាពមិនគួរឱ្យទុកចិត្តនៃស្ថិរភាពតម្លៃ និងការព្យាករតម្លៃ។

# ការដំណើរការរបស់ផ្សារ

សន្ទស្សន៍ដំណើរការផ្សារ (MFI)[1] វាស់វែងពីដំណើរការរបស់ផ្សារដែលបានតាមដាន ដោយផ្អែកលើសមាសធាតុសំខាន់ៗ៖ ភាពចម្រុះនៃទំនិញចាំបាច់ ភាពអាចរកបានជាក់ស្តែងនៃទំនិញក្នុងបរិមាណគ្រប់គ្រាន់ តម្លៃដែលអាចព្យាករបាននិងមានស្ថេរភាព និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់។ ពិន្ទុ MFI នៅចន្លោះពី០ ដល់១០ ដែលពិន្ទុកាន់តែខ្ពស់បង្ហាញពីដំណើរការកាន់តែល្អ។

ក្នុងខែកុម្ភៈ ឆ្នាំ២០២៣ ដំណើរការរបស់ផ្សារមានបម្រែបម្រួលតិចតួច ដោយសារតែការធ្លាក់ចុះនេះមកពីភាពមានទំនិញសំខាន់ៗ និងភាពមិនអាចព្យាករបាននៃតម្លៃនៅផ្សារ។ នេះក៏ទំនងជាបណ្តាលមកពីភាពមិនច្បាស់លាស់នៃតម្លៃប្រេងឥន្ធនៈ។ ប្រធានទីផ្សារ និងអ្នកលក់ដែលបានសម្ភាសន៍ចំនួន ២,៩% បានរាយការណ៍ពីការកើនឡើងតម្លៃផ្គត់ផ្គង់នៅក្នុងខែកុម្ភៈ ឆ្នាំ២០២៣ ធៀបនឹង ៣,៥% ក្នុងខែមុន។




*[1] សមាសធាតុទាំងបួន ដូចជា ភាពចម្រុះនៃទំនិញ ភាពមានស្បៀង តម្លៃស្បៀង និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់នៅក្នុងសន្ទស្សន៍ដំណើរការផ្សារសង្ខេប គឺជាសន្ទស្សន៍ ដែលមានពីលេខ០ ដល់លេខ១០ ហើយតម្លៃកាន់តែខ្ពស់ បង្ហាញថា ផ្សារមានដំណើរការកាន់តែល្អកំឡុងពេលតាមដាន។ សន្ទស្សន៍ដំណើរការផ្សារជារួមគឺជាការបញ្ចូលគ្នានៃសមាសធាតុទាំងបួន។ លម្អិតពីវិធីសាស្ត្ររបស់សន្ទស្សន៍ដំណើរការផ្សារ។ ចាប់ពីពាក់កណ្តាលខែកញ្ញា ឆ្នាំ ២០២២មក ព័ត៌មានស្តីពីទំនិញមិនមែនស្បៀងអាហារក៏ត្រូវបានបញ្ចូលទៅក្នុងការវិភាគនេះដែរ។*

# ការទៅផ្សារ៖ ទិន្នាការអតិថិជន

ប្រធានផ្សារ និងអ្នកលក់តាមបណ្តាផ្សារទាំង៥៦ (ផ្សារចំនួន១១ ទើបបន្ថែមក្នុងខែកញ្ញា) ដែលបានតាមដានតម្លៃនៅក្នុងប្រទេសកម្ពុជាត្រូវបានសម្ភាសន៍ស្តីពីភាពងាយស្រួលក្នុងការធ្វើដំណើរទៅផ្សារ និងចំនួនអតិថិជនទៅផ្សាររបស់ពួកគាត់នៅសប្តាហ៍ទី១ និងសប្តាហ៍ទី៣ នៃខែនីមួយៗ។

ចំនួនអតិថិជនបានទៅផ្សារបានថយចុះគួរឱ្យកត់សម្គាល់ក្នុងខែកុម្ភៈ ឆ្នាំ២០២៣។




បម្រែបម្រួល[1]នៃចំនួនអតិថិជនមកផ្សារ

[1]*តម្លៃលេខបង្ហាញពីបម្រែបម្រួលនៃចំនួនអតិថិជនត្រូវបានគណនាដោយប្រើសន្ទស្សន៍កំណើន/តំហាយ (diffusion index) ដើម្បីតាមដានពីការប្រែប្រួលអតិថិជនមកផ្សារក្នុងសេរីពេលវេលា។*

# ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របស់ WFP ត្រូវបានគណនាដើម្បីជាជំនួយក្នុងការបកស្រាយផលប៉ះពាល់នៃការប្រែប្រួលតម្លៃស្បៀងប្រចាំខែលើតម្លៃរបបអាហារប្រក់បដោយអាហារូបត្ថម្ភដែលបានទទួលទាននៅកម្ពុជា។

ក្នុងខែកុម្ភៈ ឆ្នាំ២០២៣ តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានបានកើនឡើងបន្តិច ១,១% ធៀបនឹងខែមុន (MoM) ដល់តម្លៃ ១០៧.៦១០ រៀល/ម្នាក់/ខែ (ប្រហែល ២៦,២ ដុល្លារ) ហើយខ្ពស់ជាងខែដដែលកាលពីឆ្នាំមុន ៦,៦% (YoY)។ កញ្ចប់ស្បៀងអាហារមូលដ្ឋាននៅជនបទ (២៥,៥ ដុល្លារ) មានតម្លៃទាបជាងនៅទីប្រជុំជន (២៦,៦ ដុល្លារ)។




## កញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របបអាហារប្រចាំថ្ងៃសម្រាប់មនុស្សម្នាក់



*កញ្ចប់ស្បៀងអាហារមូលដ្ឋានមានបញ្ចូលនូវស្បៀងអាហារសំខាន់ៗ រួមមាន អង្ករចម្រុះ ត្រីផ្អក់ សាច់ជ្រូក ស៊ុតទា ប្រេងឆា ដំឡូងជ្វា និងត្រកួន ដែលផ្តល់ថាមពលអប្បបរមាចាំបាច់ចំនួន ១.៩៣៧ កាឡូរី សម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ។ កញ្ចប់ស្បៀងអាហារមូលដ្ឋានត្រូវបានវិភាគដោយផ្អែកលើកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា របស់ WFP។ សូមមើលឧបសម្ព័ន្ធទី ៣ សម្រាប់ព័ត៌មានពីវិធីសាស្ត្រ។*

# ថ្នាក់ក្រោមជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របស់ WFP មានការប្រែប្រួលទៅតាមខេត្ត និងផ្សារ។ តម្លៃកញ្ចប់ស្បៀងអាហារខ្ពស់ជាងគេស្ថិតនៅផ្សារដងទង់ ក្នុងខេត្តកោះកុង គឺ ១២៦.៣១៤ រៀល/ម្នាក់/ខែ (ប្រហែល ៣០,៨ ដុល្លារ) ដែលខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ ១៧,៤%។ តម្លៃ BFB ទាបជាងគេស្ថិតក្នុងផ្សារស្ទោង ក្នុងខេត្តកំពង់ធំ គឺ ៩២.៥៩២ រៀល/ម្នាក់/ខែ (ប្រហែល ២២,៦ ដុល្លារ) ដែលទាបជាងតម្លៃមធ្យមថ្នាក់ជាតិ១៤,០%។ ផែនទីខាងក្រោមបង្ហាញពីតម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន និងបម្រែបម្រួលធៀបនឹងតម្លៃកញ្ចប់មធ្យមថ្នាក់ជាតិ។

តម្លៃកញ្ចប់ស្បៀងអាហារបម្រែបម្រួលខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ ចាប់ពី៥% ឬខ្ពស់ជាង ឡើងទៅ គឺភាគច្រើនមាននៅផ្សារនៅទីប្រជុំជន ជាងនៅក្នុងផ្សារនៅជនបទ។

### តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានតាមផ្សារ ឬខេត្ត ធៀបនឹងតម្លៃកញ្ចប់ជាមធ្យមថ្នាក់ជាតិ (ខែកុម្ភៈ ឆ្នាំ២០២៣)




| បម្រែបម្រួលពីតម្លៃមធ្យមថ្នាក់ជាតិ | ភាគរយនៃផ្សារនៅ ជនបទ | ភាគរយនៃផ្សារនៅ ទីប្រជុំជន |
|---|---|---|
| ≥ ១០% ខ្ពស់ជាង | ០,០% | ១០០,០% |
| ៥% ទៅ ១០% ខ្ពស់ជាង | ២០,០% | ៨០,០% |
| < ៥% ខ្ពស់ជាង | ៤១,៧% | ៥៨,៣% |
| < ៥% ទាបជាង | ៥៨,៨% | ៤១,២% |
| ៥% ទៅ ១០% ទាបជាង | ៤០,០% | ៦០,០% |
| ≥ ១០% ទាបជាង | ៥០.០% | ៥០,០% |

# ថ្នាក់ជាតិ៖ ប្រាក់ឈ្នួលពលកម្ម និងកម្លាំងទិញស្បៀងអាហារ

ប្រាក់ឈ្នួលពលកម្មសម្រាប់កម្មករក្នុងវិស័យកសិកម្ម និងសំណង់ត្រូវបានប្រមូលជារៀងរាល់ខែនៅទូទាំងប្រទេសដោយ AMO។ ក្នុងខែកុម្ភៈ ឆ្នាំ២០២៣ តម្លៃមធ្យមថ្នាក់ជាតិប្រាក់ឈ្នួលពលកម្មបានកើនឡើងដល់ ៣៥.៦២២ រៀលក្នុងមួយថ្ងៃ (ប្រហែល ៨,៧ ដុល្លារ +៩,២% ធៀបខែមុន និង +៤,៦% ធៀបខែដដែលកាលពីឆ្នាំមុន)។

កម្លាំងទិញស្បៀងអាហារ (ToT) ត្រូវបានប្រើសម្រាប់វាយតម្លៃពីកម្លាំងទិញស្បៀងអាហាររបស់គ្រួសារ ហើយត្រូវបានវាស់វែងដោយប្រើផលធៀបរវាងអត្រាប្រាក់ឈ្នួលកម្មករគ្មានជំនាញ និងតម្លៃមធ្យមកញ្ចប់ស្បៀងអាហារមូលដ្ឋាន។ វាបង្ហាញពីបរិមាណស្បៀងអាហារ ដែលកម្មករគ្មានជំនាញអាចទិញដោយប្រើប្រាស់ប្រាក់ឈ្នួលក្នុងមួយថ្ងៃរបស់គាត់។ ក្នុងខែកុម្ភៈ ឆ្នាំ២០២៣ ជាមួយនឹងការកើនឡើងនៃប្រាក់ឈ្នួលពលកម្ម ToT ក៏បានកើនឡើងដល់ ១០,១ (ខ្ពស់ជាងខែមុន ៧,៩% តែទាបជាងខែដដែលកាលពីឆ្នាំមុន ១,៩%) ដែលបង្ហាញពីកម្លាំងទិញស្បៀងអាហារខ្ពស់របស់ប្រជាជនងាយរងគ្រោះ ។

**ប្រាក់ឈ្នួលពលកម្ម** (ខែកុម្ភៈ ឆ្នាំ២០២៣)




**កម្លាំងទិញស្បៀងអាហារ** (ខែកុម្ភៈ ឆ្នាំ២០២៣)



# ថ្នាក់ជាតិ៖ និន្នាការតម្លៃអង្ករ ស៊ុតទា និងត្រកួន

ក្នុងខែកុម្ភៈ ឆ្នាំ២០២៣ តម្លៃអង្ករចម្រុះ (+២,៨%) និងតម្លៃស៊ុតទា (+២,៣%) បានកើនឡើងបន្តិច ខណៈតម្លៃត្រកួនមានស្ថេរភាព បើធៀបនឹងខែមុន។ តម្លៃអង្ករចម្រុះបានបន្តកើនឡើង ៣,៣% ធៀបនឹងឆ្នាំមុន (YoY) តម្លៃស៊ុតទាបានកើនឡើងគួរឱ្យកត់សម្គាល់ គឺ ១២,៩% YoY ហើយតម្លៃត្រកួនបានកើនឡើងគួរឱ្យគត់សម្គាល់ គឺ ២៧,២% YoY។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃនៃស្បៀងអាហារផ្សេងៗទៀត។*




*[1]ត្រកួនគឺបន្លែដែលត្រូវបានទទួលទានជាទូទៅនៅប្រទេសកម្ពុជា ហើយនិន្នាការតម្លៃរបស់វាមិនបង្ហាញពីការឡើងចុះតម្លៃបន្លែផ្សេងទៀតនៅក្នុងឧបសម្ព័ន្ធនោះទេ។*
*[2]តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ*

# ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា

ក្នុងខែកុម្ភៈ ឆ្នាំ២០២៣ តម្លៃត្រីផ្ទក់បានកើនឡើងបន្តិច (+៣,១%) ប៉ុន្តែតម្លៃសាច់ជ្រូក (-២,៣%) និងប្រេងឆា (-១,៨%) បន្តនិន្នាការថយចុះ។ តម្លៃប្រេងឆាទាបជាងកាលពីឆ្នាំមុនចំនួន -៤,៣% ហើយតម្លៃសាច់ជ្រូកទាបជាងកាលឆ្នាំមុនចំនួន -១៨,៧%។ ទោះយ៉ាងណា ត្រីផ្ទក់នៅតែមានតម្លៃខ្ពស់ជាងរយៈពេលដូចគ្នាកាលពីឆ្នាំមុន (+១៨,៨%)។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃស្បៀងអាហារផ្សេងៗទៀត។*




[1]តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ

# ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ និងទីប្រជុំជន

នៅក្នុងខែកុម្ភៈ ឆ្នាំ២០២៣ ស្បៀងអាហារសំខាន់ៗ ដែលបានកំពុងតាមដាន នៅទីប្រជុំជនមានតម្លៃមធ្យមលក់រាយខ្ពស់ជាងនៅជនបទ លើកលែងអង្ករចម្រុះ និងស៊ុតទា (តារាង១)។

ប្រៀបធៀបនឹងខែមុន តម្លៃមធ្យមលក់រាយស្បៀងអាហារនៅក្នុងផ្សារកំពុងតាមដាន មានបម្រែបម្រួលតិចតួច (<៥,០%) និងមានទិសដៅបម្រែបម្រួលដូចគ្នា (លើកលែងតែសាច់ជ្រូក ត្រកួន និងដំឡូងជ្វា) ទាំងនៅទីប្រជុំជន និងទីជនបទ បើធៀបនឹងខែមុន។ តម្លៃដំឡូងជ្វាពណ៌លឿងបានកើនឡើងបង្គួរនៅជនបទ គឺ ៨,៨% ធៀបខែមុន តែបានថយចុះបន្តិចនៅទីប្រជុំជន គឺ ២,២%)។

**តារាង១៖ តម្លៃលក់រាយ (រៀល) នៅជនបទ និងទីប្រជុំជន**

| | ទីប្រជុំជន | ជនបទ |
|---|---|---|
| អង្ករ (គក) | ២.១០៧ | ២.១៧៨ |
| ត្រីផ្ទក់ (រស់) (គក) | ១១.៣៣៩ | ១០.៦៥៦ |
| សាច់ជ្រូក (គក) | ១៦.២២២ | ១៥.៧៩៩ |
| ស៊ុតទា (១០គ្រាប់) | ៥.៥១៣ | ៥.៥២៥ |
| ប្រេងឆា (៥លីត្រ) | ២៩.៥៨១ | ២៩.០៧១ |
| ត្រកួន (គក) | ៣.៣៣៣ | ២.៩៤៣ |
| ដំឡូងជ្វាពណ៌លឿង | ៣.២១៤ | ៣.០៦១ |

## បម្រែបម្រួលប្រចាំខែ (%) នៃតម្លៃលក់រាយស្បៀងអាហារសំខាន់ៗ

### ខែមករា ឆ្នាំ២០២៣ និង ខែកុម្ភៈ ឆ្នាំ២០២៣

ជនបទ




ទីប្រជុំជន




*[1] ទិន្នន័យនេះទទួលបានពីផ្សារចំនួន៥៦។ សូមមើលផ្នែកវិធីសាស្ត្រសម្រាប់ព័ត៌មានលម្អិត។*
*[2] តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ*

# ការតាមដានរដូវកាល៖ របាយទឹកភ្លៀង

កម្ពស់ទឹកភ្លៀងជាមធ្យមថ្នាក់ជាតិសរុបចាប់ពីខែធ្នូ ឆ្នាំ២០២២ ដល់ខែកុម្ភៈ ឆ្នាំ២០២៣ មានកម្រិតខ្ពស់ជាងមធ្យមភាគច្រើនឆ្នាំបន្តិច (ក្រាហ្វិកខាងក្រោមខាងឆ្វេង)។ ប៉ុន្តែសរុបទឹកភ្លៀងក្នុងខែកុម្ភៈមានកម្រិតទាបជាងមធ្យមភាគច្រើនឆ្នាំ និងមានរបាយមិនស្មើគ្នានៅទូទាំងប្រទេស (ផែនទីខាងក្រោមខាងស្តាំ)។ ផ្នែកភាគច្រើនក្នុងប្រទេសទទួលបានទឹកភ្លៀងទាបជាងធម្មតា ខណៈដែលខេត្តភាគខាងកើត តាមបណ្តោយទន្លេមេគង្គ ដូចជាខេត្តកំពង់ចាម ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង និងរតនគិរី ទទួលបានទឹកភ្លៀងចន្លោះពីធម្មតាទៅខ្ពស់ជាងធម្មតា។

យោងតាមព័ត៌មានព្យាករណ៍តាមរដូវកាលរបស់ IRI Columbia University ទូទាំងប្រទេសត្រូវបានរំពឹងថានឹងទទួលបានទឹកភ្លៀងលើសពីកម្រិតធម្មតាពីតិចទៅបង្គួរចាប់ពីខែមីនា ដល់ខែឧសភា ឆ្នាំ២០២៣។ ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) បានព្យាករថា រដូវវស្សា ឆ្នាំ២០២៣ នឹងចាប់ផ្តើមនៅក្នុងសប្តាហ៍ទី១ ខែឧសភា នៅតំបន់ទំនាបកណ្តាល និងតំបន់ឆ្នេរសមុទ្រ និងនៅពាក់កណ្តាលខែឧសភា នៅផ្នែកដទៃទៀតនៃប្រទេស។

## បរិមាណទឹកភ្លៀងមធ្យមថ្នាក់ជាតិ (គិតត្រឹមខែកុម្ភៈ ឆ្នាំ២០២៣) និងប្រតិទិនដាំដុះតាមរដូវកាល




| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ស្រូវរដូវប្រាំង | ដាំដុះ | | ប្រមូលផល | | | | | | | | រៀបចំដី និងសាបព្រោះ | |
| ស្រូវរដូវវស្សា | ប្រមូលផល | | | | រៀបចំដី និងសាបព្រោះ | | ស្ទូង / ដាំដុះ | | | | ប្រមូលផល | |

*ប្រភព៖ ទិន្នន័យទឹកភ្លៀងពី CHIRPS និងវិភាគដោយ WFP*

## ភាពមិនប្រក្រតីនៃទឹកភ្លៀង ក្នុងខែកុម្ភៈ ឆ្នាំ២០២៣




*ប្រភព៖ ទិន្នន័យទឹកភ្លៀងពី CHIRPS និងវិភាគដោយ WFP*

# **ការតាមដានរដូវកាល៖** ស្ថានភាពរុក្ខជាតិ និងដំណាំ

ស្ថានភាពធាតុអាកាសអំណោយផល និងការផ្គត់ផ្គង់ទឹកល្អប្រសើរតាមធារាសាស្ត្រដោយសារមានទឹកភ្លៀងគ្រប់គ្រាន់ ធ្វើឱ្យរុក្ខជាតិមានសុខភាពល្អ។ ក្នុងខែកុម្ភៈ ឆ្នាំ២០២៣ ស្ថានភាពរុក្ខជាតិដែលមានសុខភាពប្រសើរជាងធម្មតាគ្របដណ្តប់នៅទូទាំងប្រទេស (ផែនទីខាងស្តាំ) ជាពិសេស តំបន់ជុំវិញបឹងទន្លេសាប និងតំបន់ទំនាបកណ្តាល ជាតំបន់ដែលដាំដុះស្រូវរដូវប្រាំងច្រើន។ ផ្ទុយមកវិញ ស្ថានភាពរុក្ខជាតិដែលមានសុខភាពទាបជាងធម្មតាត្រូវបានអង្កេតឃើញនៅតំបន់ភាគខាងជើង និងខាងលិចប្រទេស។

គិតត្រឹមខែកុម្ភៈ ឆ្នាំ២០២៣ ការដាំដុះស្រូវរដូវប្រាំងសម្រេចបានប្រមាណ ៦៧៣.៥៧៩ ហិកតា ស្មើនឹង ១៣៦% នៃផែនការជាតិប្រចាំឆ្នាំនេះបើយោងតាមក្រសួងធនធានទឹក និងឧតុនិយម (MoWRAM)។ ក្នុងរយៈពេលដូចគ្នា ស្រូវរដូវប្រាំងប្រមាណ ២៥% បានប្រមូលផលរួចរាល់ទទួលបានទិន្នផល ៤,៥ តោន ក្នុងមួយហិកតា (ASEAN Food Security Information System)។ ផលិតកម្មដំណាំស្រូវក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ២០២២/២០២៣ ត្រូវបានប៉ាន់ស្មានប្រមាណ ១២,២ លានតោន ដែលខ្ពស់ជាងឆ្នាំមុនបន្តិច (០,១៣%)។

### ភាពមិនប្រក្រតីនៃសន្ទស្សន៍ភាពខុសគ្នានៃរុក្ខជាតិ (NDVI) ក្នុងខែកុម្ភៈ ឆ្នាំ២០២៣




*ប្រភព៖ NDVI ពី MODIS និងវិភាគដោយ WFP*
*ចំណាំ៖ ការបកស្រាយពីស្ថានភាពរុក្ខជាតិមានកម្រិតសម្រាប់តំបន់គ្របដណ្តប់ដោយពពកឬមិនមានទន្និន័យ*

# ពាណិជ្ជកម្ម

គិតត្រឹមខែកុម្ភៈ ស្ថិតិសរុបនៃពាណិជ្ជកម្មក្នុងឆ្នាំ២០២៣ ទាបជាងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ក្នុងរយៈពេលពីរខែដំបូងឆ្នាំ២០២៣ ការនាំចេញផ្លូវការសរុបរបស់កម្ពុជាមានតម្លៃ ៣.២៨៥,៣ លានដុល្លារ ដែលទាបជាងរយៈពេលដដែលកាលពីឆ្នាំមុនប្រមាណ ៨,៦%។ ជាមួយគ្នាដែរ ការនាំចេញអង្ករមានចំនួន ៩៧.៤៦៧ តោន (មានតម្លៃស្មើ ៧២,៦៧ លានដុល្លារ) បានថយចុះ ៥,៤% ធៀបនឹងរយៈពេលដដែលកាលពីឆ្នាំមុន ហើយការនាំចេញស្រូវមានចំនួន ៨៧១.៣១៩ តោន (មានតម្លៃស្មើនឹង២១៧,៨២ លានដុល្លារ) (ដកស្រង់ដោយកាសែតប្រុស្ញែរ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣)។ សហព័ន្ធស្រូវអង្ករកម្ពុជា (CRF) បានសន្យាថានឹងជម្រុញការនាំចេញអង្ករឱ្យបាន ៧៥០.០០០ តោន ក្នុងឆ្នាំ២០២៣នេះ និង ១ លានតោន ក្នុងឆ្នាំ២០២៥ (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០២៣)។

ក្នុងរយៈពេលពីរខែដំបូងឆ្នាំ២០២៣ ប្រទេសកម្ពុជាបាននាំចូលជាផ្លូវការសរុបមានតម្លៃ ៣,៥៦២,៥ លានដុល្លារ ក្នុងនោះមានទំនិញជាស្បៀងអាហារចំនួន ១៨៨,៩ លានដុល្លារ ដែលរួមមាន៖ ធញ្ញជាតិសរុបចំនួន ៩,៦ លានដុល្លារ (-៣០,២% ធៀបឆ្នាំមុន) និងអាហារដទៃទៀត (ដូចជា៖ សាច់/សំណល់សាច់/គ្រឿងក្នុងដែលអាចបរិភោគបាន បន្លែដែលអាចបរិភោគបាន ឫស/មើម និងខ្លាញ់សត្វ ប្រេងរុក្ខជាតិ) ចំនួន ១៧៩,៣ លានដុល្លារ (+២,៥%)។ ប្រទេសកម្ពុជាក៏បាននាំចូលជីកសិកម្មចំនួន ៣២,១ លានដុល្លារ (+២៦,១% ធៀបឆ្នាំមុន) ក្នុងរយៈពេលដូចគ្នា។

កម្មវិធីរយៈពេល៧ឆ្នាំគាំទ្រសេដ្ឋកិច្ចជនបទ និងពាណិជ្ជកម្មផលិតផលកសិកម្ម ត្រូវបានផ្តើមអនុវត្ត និងរៀបចំឡើងដើម្បីជំរុញពាណិជ្ជកម្មផលិតផលកសិកម្មសំខាន់ៗ ដូចជា បន្លែ ផ្លែឈើ បសុបក្សី ជាដើម ហើយត្រូវបានរំពឹងទុកថានឹងជួយដល់កសិករខ្នាតតូចចំនួន ១២៥.០០០ នាក់ (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០២៣)។

បន្ទាប់ពីបានប្រកាសពីការបញ្ចប់យ៉ាងសំខាន់នៃការចរចានៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និងទី៤១ កិច្ចព្រមព្រៀងធ្វើឱ្យប្រសើរឡើងនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ (AANZFTA) នឹងត្រូវចុះហត្ថលេខានៅខែសីហា ឆ្នាំ២០២៣ (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០២៣) ហើយត្រូវបានរំពឹងទុកថានឹងជំរុញសេដ្ឋកិច្ចក្រោយការរាតត្បាតជំងឺ និងធ្វើឱ្យខ្សែច្រវ៉ាក់ផ្គត់ផ្គង់មានភាពធន់។

## សមតុល្យពាណិជ្ជកម្មកម្ពុជា (គិតជាលានដុល្លារ) នៃក្រុមទំនិញសំខាន់ៗ ខែកុម្ភៈ ឆ្នាំ២០២៣




*ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ថ្ងៃទី ១០ ខែមីនា ឆ្នាំ២០២៣*

# ការឆ្លើយតបផ្នែកនយោបាយ

## គោលនយោបាយឆ្លើយតបលើការគាំពារសង្គម

ផែនការស្តារសេដ្ឋកិច្ចពីការរាតត្បាតកូវីដ-១៩ របស់រដ្ឋាភិបាលមានបញ្ចូលនូវវិធានការគាំពារសង្គមនានា។ ចាប់ពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ រដ្ឋាភិបាលបានអនុវត្តកម្មវិធីជំនួយសាច់ប្រាក់ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះនៅទូទាំងប្រទេស ដែលប៉ះពាល់ដោយការរាតត្បាតកូវីដ-១៩។ គ្រួសារក្រីក្រប្រមាណ ៧០៥.៦១៣ គ្រួសារ (ប្រមាណ ២,៧៨ លាននាក់) បានទទួលសាច់ប្រាក់ឧបត្ថម្ភ សរុបជាទឹកប្រាក់ចំនួន ៩៦២,៩៧ លានដុល្លារ គិតចាប់ពីដំណើរការកម្មវិធីដំបូងនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៣។ កម្មវិធីនេះនឹងបន្តក្នុងឆ្នាំ២០២៣។

<u>កម្មវិធីឧបត្ថម្ភសាច់ប្រាក់របស់រដ្ឋាភិបាលសម្រាប់គ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់</u> ដែលបានផ្តើមអនុវត្តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ នឹងបញ្ចប់នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ជំនួសមកវិញដោយកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងកំឡុងពេលមានសម្ពាធអតិផរណា។

គិតត្រឹមថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ រោងចក្រកាត់ដេរចំនួន ៧១ ដែលមាន<u>កម្មករ/កម្មការនីចំនួន ៣២.០០០ នាក់</u> បានព្យួរកិច្ចសន្យាការងារ ដោយសារតែមានតម្រូវការទាបពីសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុបកំឡុងពេលវិបត្តិអតិផរណាសកល។ នៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ នាយករដ្ឋមន្ត្រីបានសម្រេចផ្តើមអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ដោយសហការជាមួយម្ចាស់រោងចក្រកាត់ដេរ និងវាយណភណ្ឌ ដើម្បីផ្តល់ជំនួយហិរញ្ញវត្ថុដល់កម្មករ/កម្មការនីដែលត្រូវបានព្យួរកិច្ចសន្យា។ វានឹងចាប់ផ្តើមពីខែមេសា ឆ្នាំ២០២៣ ហើយនាយករដ្ឋមន្ត្រីក៏បានប្រកាសពីការបង្កើនប្រាក់ឧបត្ថម្ភ សម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំផងដែរ (<u>ដកស្រង់ដោយកាសែតហ្វ្រេសញូវ ថ្ងៃទី៧ ខែមីនា ឆ្នាំ ២០២៣</u>)។

## គោលនយោបាយឆ្លើយតបផ្នែកសេដ្ឋកិច្ច

ក្រោមក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ ឆ្នាំ២០២១ - ២០២៣ របស់រដ្ឋាភិបាល ប្រាក់កម្ចីចំនួន <u>៩៦.៥ លានដុល្លារ</u> ស្មើនឹង៣១% នៃថវិកាសរុប ១៥០ លានដុល្លារ ត្រូវបានផ្តល់សម្រាប់ការស្តារ និងលើកកម្ពស់វិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ច គិតត្រឹមថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣។

ក្រសួងពាណិជ្ជកម្មបានចេញប្រកាស នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពីការដកចេញផលិតផលអាហារដែលមិនមានសុវត្ថិភាព ឬផលិតផលដែលមិនគោរពតាមលក្ខខណ្ឌបច្ចេកទេសរបស់កម្ពុជា បើមិនដូច្នោះនឹងផ្អាកអាជីវកម្មបណ្តោះអាសន្ន (<u>ដកស្រង់ដោយកាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ ២០២៣</u>)។

## ការចាក់វ៉ាក់សាំងកូវីដ-១៩

ផ្អែកតាម<u>ក្រសួងសុខាភិបាល</u> គិតត្រឹមថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ ពលរដ្ឋអាយុលើសពី៣ឆ្នាំ ជាង ១៥,២៧ លាននាក់ (៥០,៥% ជាស្ត្រី) បានទទួលវ៉ាក់សាំងកូវីដ-១៩ យ៉ាងតិចដូសទី១ សម្រេចតាមផែនការថ្នាក់ជាតិ ១០៤,៣% (៩៥,៤៧% នៃប្រជាជនសរុប)។




***ប្រភព៖** <u>ទំព័រហ្វេសប៊ុកផ្លូវការរបស់គាំពារសង្គមកម្ពុជា ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២២</u>*




***ប្រភព៖** ក្រសួងសុខាភិបាលកម្ពុជា ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣*

# វិធីសាស្ត្រ និងទីតាំងផ្សារ

**Markets for Remote Data Collection**




WFP ចាប់ផ្តើមតាមដានតម្លៃស្បៀងអាហារ នៅតាមបណ្តាផ្សារមួយចំនួនតាមរយៈទូរស័ព្ទ តាំងពីខែវិច្ឆិកា ឆ្នាំ២០១៩ មកម្ល៉េះ។ អ្នកសម្ភាសន៍តាមទូរស័ព្ទ ដែលបានទទួលការបណ្តុះបណ្តាលច្បាស់លាស់បានទំនាក់ទំនងទៅកាន់អាជីវករនានា រៀងរាល់មួយខែម្តង ដើម្បីប្រមូលតម្លៃទំនិញចំនួន៣៦ប្រភេទ ក្នុងផ្សារចំនួន១៤ នៅទីប្រជុំជន និងជនបទនៃខេត្តបាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ឧត្តរមានជ័យ សៀមរាប ព្រះវិហារ និងស្ទឹងត្រែង។

នៅក្រោមកិច្ចសហការជាមួយការិយាល័យទីផ្សារកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខែមីនា ឆ្នាំ២០២០ WFP បានអង្កេតតម្លៃទីផ្សារនៅក្នុងផ្សារចំនួន៣១បន្ថែមទៀត ដើម្បីប្រមូលទិន្នន័យមូលដ្ឋាន និងដើម្បីពង្រីកចំនួនផ្សារគ្របដណ្តប់។ យើងបានប្រមូលតម្លៃស្បៀងចំនួន១៦ប្រភេទ និងព័ត៌មានពីដំណើរការរបស់ផ្សារទាំងនោះផងដែរ។

ចាប់ពីពាក់កណ្តាលខែមេសាឆ្នាំ២០២០មក WFP បានពង្រីកការតាមដានតម្លៃទីផ្សារតាមរយៈទូរស័ព្ទក្នុងផ្សារចំនួន៤៥ ហើយក៏បានបង្កើនចំនួនប្រមូលទិន្នន័យ ២ដងក្នុងមួយខែផងដែរ (ឧ. សប្តាហ៍ទី១ និងទី៣នៃខែនីមួយៗ)។

នៅពាក់កណ្តាលខែកញ្ញា ឆ្នាំ២០២២ WFP បន្ថែមទំនិញជាស្បៀងអាហារ និងមិនមែនស្បៀងអាហារចំនួន ១៥ (មើលឧបសម្ព័ន្ធ) និងពង្រីកផ្សារគ្របដណ្តប់ដល់ ៥៦ ផ្សារ។

# ឧបសម្ព័ន្ធទី១៖ បម្រែបម្រួលតម្លៃលក់រាយ

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ១.១ អង្ករចម្រុះ | Kg | 2,137 | → 2.3% | → 1.8% | → 3.3% |
| ២.១ ត្រីផ្ទក់(រស់) | Kg | 11,106 | → 3.1% | → 4.0% | ↑ 18.8% |
| ២.២ ត្រីប្រា(រស់) | Kg | 7,098 | → 3.9% | → -2.6% | ↑ 7.1% |
| ២.៣ ត្រីអណ្ដែង(រស់) | Kg | 7,859 | → 2.8% | → -0.5% | ↑ 10.2% |
| ២.៤ ត្រីងៀត(ផ្ទក់) | Kg | 26,722 | → 1.7% | ↑ 6.3% | ↑ 10.1% |
| ២.៥ ប្រហុក | Kg | 9,717 | ↑ 8.3% | ↓ -5.1% | ● |
| ៣.១ សាច់ជ្រូកពាជាន់ | Kg | 16,033 | → -2.3% | ↓ -6.4% | ↓ -18.7% |
| ៣.២ សាច់គោឃារ | Kg | 19,358 | → -0.8% | → -1.0% | ● |
| ៣.៣ សាច់មាន់ (បីសាសន៍) | Kg | 14,109 | → -0.6% | ↑ 7.0% | ● |
| ៤.១ ស៊ុតទា | 10 eggs | 5,517 | → 2.8% | ↓ -12.6% | ↑ 12.9% |
| ៤.២ ស៊ុតទាប្រៃ | 10 eggs | 6,840 | → -1.5% | ↓ -9.4% | → 4.2% |
| ៥.១ ប្រេងឆា | 5 litres | 29,403 | → -1.4% | ↓ -7.4% | → -4.3% |
| ៦.១ អំបិលម៉ត់អ៊ីយូត | Kg | 1,228 | ↓ -8.0% | → -3.5% | → 0.6% |
| ៦.២ ទឹកត្រី (រូបបង្គងប៉ាក) | 730 ml | 3,351 | → -0.9% | → 0.5% | ● |
| ៧.១ សណ្តែកដី* | Kg | 9,869 | → -0.9% | → -2.0% | → -1.5% |
| ៧.២ សណ្តែកសៀង | Kg | 5,421 | → 0.8% | ↑ 8.8% | ● |
| ៧.៣ សណ្តែកខៀវ | Kg | 6,071 | → 2.6% | → 3.8% | ● |
| ៨.១ ត្រកួន | Kg | 3,203 | → 0.4% | ↓ -16.0% | ↑ 27.2% |
| ៨.២ ការ៉ុត* | Kg | 3,441 | → -1.6% | → -3.6% | ↓ -7.5% |
| ៨.៣ ស្ពៃក្តោប* | Kg | 5,124 | → 2.6% | ↓ -7.6% | ↑ 14.1% |
| ៨.៤ ស្លឹកម្រុំ* | Kg | 5,221 | → 2.8% | → -0.5% | ↑ 14.2% |
| ៨.៥ ម្ទេសក្រញាញ់* | Kg | 4,339 | ↑ 23.8% | ↓ -16.1% | ↑ 14.9% |
| ៨.៦ ម្ទេសតឿ* | Kg | 4,007 | ↑ 17.8% | ↓ -14.2% | ↑ 7.0% |
| ៨.៧ ម្ទេសចង្កឹះ | Kg | 3,724 | ↑ 25.9% | ↓ -7.7% | ↑ 9.1% |
| ៨.៨ ម្ទេសខៀវ* | Kg | 3,584 | ↑ 12.8% | ↓ -14.7% | → 2.0% |
| ៨.៩ ខ្ទឹមដូង* | Kg | 4,258 | → -0.5% | ↓ -21.2% | ↑ 13.2% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ៨.១០ ស្លឹកងប់* | Kg | 5,203 | → -1.3% | ↓ -17.1% | ↓ -6.0% |
| ៨.១១ ត្រយល្ពៅ* | Kg | 4,765 | → -0.7% | ↓ -11.4% | ↓ -9.1% |
| ៨.១២ ផ្លែល្ពៅ* | Kg | 2,746 | → -4.8% | ↓ -7.2% | ↑ 11.1% |
| ៨.១៣ ឃ្លោក* | Kg | 2,500 | ● | ↓ -17.9% | ↑ 7.1% |
| ៨.១៤ ត្រឡាច | Kg | 2,857 | ↑ 25.1% | ↓ -16.5% | ↑ 14.7% |
| ៨.១៥ ត្រប់វែង | Kg | 3,449 | ↓ -8.7% | ↓ -15.7% | ↑ 19.7% |
| ៨.១៦ ត្រប់ស្រួយ* | Kg | 3,380 | ↓ -8.9% | ↓ -19.7% | ↑ 5.6% |
| ៨.១៧ ប៉េងប៉ោះ* | Kg | 3,538 | ↓ -18.1% | ↓ -21.3% | ↑ 11.5% |
| ៨.១៨ននោងមូល | Kg | 3,170 | ↑ 5.2% | ↓ -13.4% | ↑ 15.5% |
| ៨.១៩ ននោងជ្រុង* | Kg | 3,203 | ↑ 6.1% | ↓ -14.1% | ↑ 13.9% |
| ៨.២០ ល្ពងខ្ទី* | Kg | 1,973 | ↑ 15.9% | ↑ 28.1% | ↑ 31.7% |
| ៨.២១ សណ្តែកកួរ | Kg | 3,943 | → 3.7% | ↓ -20.3% | ↑ 6.2% |
| ៨.២២ ត្រយូងចេក* | Kg | 2,351 | → 4.2% | → 0.4% | → 0.0% |
| ៨.២៣ ផ្កាខាត់ណា* | Kg | 5,863 | → 3.7% | ↓ -29.7% | ↑ 20.3% |
| ៨.២៤ ដើមខាត់ណា* | Kg | 4,258 | ↓ -6.8% | ↓ -33.2% | ↓ -6.3% |
| ៨.២៥ ដំឡូងពណ៌លឿង* | Kg | 3,168 | → 0.5% | ↑ 27.1% | ↑ 32.6% |
| ៨.២៦ ខ្ទឹមសរ | Kg | 5,434 | ↑ 5.5% | → 4.4% | ● |
| ៨.២៧ អំពិលទុំ (មានគ្រាប់) | Kg | 4,055 | → -1.4% | ↓ -8.4% | ● |
| ៩.១ ចេកណាំវ៉ាទុំ | Kg | 2,186 | → 1.4% | → 2.7% | ● |
| ៩.២ ស្វាយកែវរមៀតទុំ | Kg | 2,250 | ↓ -28.9% | → 0.0% | ● |
| ១០.១ ទឹកដោះគោស្រស់ | 140 ml | 1,602 | → -2.8% | ↓ -6.9% | ● |
| ១១.១ កូកាកូឡា | 330 ml | 2,016 | → 1.4% | ↑ 5.0% | ● |
| ៧.១ សាំងធម្មតា | litre | 4,423 | → 4.5% | → 1.6% | ● |
| ៧.២ ម៉ាស៊ូត | litre | 4,506 | → -0.4% | ↓ -9.9% | ● |
| ៨.១ ជីអ៊ុយរ៉េ | Kg | 3,184 | ↓ -9.0% | ↓ -13.6% | ● |

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្តែង ឧ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

** តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្តល់អាហារលេតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។*

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

- ↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%
- → ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%
- ↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%
- ● គ្មានតម្លៃកត់ត្រា

# ឧបសម្ព័ន្ធទី២៖ បម្រែបម្រួលតម្លៃលក់ដុំ

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ១.១ អង្ករចម្រុះ | Kg | 1,984 | → 2.3% | → 2.6% | → 3.6% |
| ២.១ ត្រីផ្ទក់(រស់) | Kg | 9,916 | → 1.1% | → 3.1% | ↑ 18.5% |
| ២.២ ត្រីប្រា(រស់) | Kg | 6,380 | → 4.7% | → 0.0% | ↑ 7.1% |
| ២.៣ ត្រីអណ្តែង(រស់) | Kg | 6,995 | → 1.5% | → -0.5% | ↑ 8.3% |
| ២.៤ ត្រីងៀត(ផ្ទក់) | Kg | 24,561 | → 1.3% | ↑ 5.4% | ↑ 10.1% |
| ២.៥ ប្រហុក | Kg | 8,496 | ↑ 7.3% | ↓ -6.7% | ● |
| ៣.១ សាច់ជ្រូកពាក់កណ្ដាលខ្លាញ់ | Kg | 14,569 | → -2.9% | ↓ -7.4% | ↓ -20.1% |
| ៣.២ សាច់គោឃរារ | Kg | 17,435 | → -1.9% | → -2.7% | ● |
| ៣.៣ សាច់មាន់ (បីសាសន៍) | Kg | 12,938 | → -1.3% | ↑ 8.6% | ● |
| ៤.១ ស៊ុតទា | 10 eggs | 5,068 | → 4.0% | ↓ -13.5% | ↑ 12.1% |
| ៤.២ ស៊ុតទាប្រៃ | 10 eggs | 6,354 | → -1.0% | ↓ -10.6% | → 3.8% |
| ៥.១ ប្រេងឆា | 5 litres | 27,856 | → -3.4% | ↓ -9.0% | ↓ -7.0% |
| ៦.១ អំបិលម៉ត់អ៊ីយូត | Kg | 984 | ↓ -10.3% | → -2.9% | → -2.7% |
| ៦.២ ទឹកត្រី (ប្របង្គងប៉ាក) | 730 ml | 2,988 | → -1.2% | → 0.5% | ● |
| ៧.១ សណ្តែកដី* | Kg | 8,913 | → -3.4% | → -2.4% | → -3.6% |
| ៧.២ សណ្តែកសៀង | Kg | 4,961 | → -1.3% | ↑ 6.3% | ● |
| ៧.៣ សណ្តែកខៀវ | Kg | 5,639 | → 3.9% | → 4.9% | ● |
| ៨.១ ត្រកួន | Kg | 2,609 | → -2.4% | ↓ -17.3% | ↑ 28.2% |
| ៨.២ ការ៉ុត* | Kg | 2,806 | → -3.8% | → -3.6% | ↓ -9.5% |
| ៨.៣ ស្ពៃក្តោបបាស* | Kg | 3,917 | → -2.9% | ↓ -8.2% | → 0.0% |
| ៨.៤ ស្ពៃក្រញ៉ាញ់* | Kg | 3,872 | → -1.5% | ↓ -12.2% | → -2.9% |
| ៨.៥ ម្ទេសក្រញាញ់* | Kg | 3,596 | ↑ 27.7% | ↓ -18.4% | ↑ 11.0% |
| ៨.៦ ម្ទេសភ្លោក* | Kg | 3,314 | ↑ 22.5% | ↓ -14.1% | → 3.3% |
| ៨.៧ ម្ទេសចង្អុល* | Kg | 3,045 | ↑ 31.2% | ↓ -6.8% | ↑ 5.7% |
| ៨.៨ ម្ទេសខៀវ* | Kg | 2,867 | ↑ 17.1% | ↓ -16.9% | → -2.4% |
| ៨.៩ ផ្ទីដូង* | Kg | 3,368 | → 2.1% | ↓ -21.3% | ↑ 9.5% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ៨.១០ ស្ពៃកង់* | Kg | 3,842 | ↓ -7.4% | ↓ -18.8% | ↓ -12.8% |
| ៨.១១ ត្រយូងល្ពៅ* | Kg | 3,522 | ↓ -5.1% | ↓ -11.2% | ↓ -21.5% |
| ៨.១២ ផ្លែល្ពៅ* | Kg | 2,125 | ↓ -11.4% | ↓ -9.9% | ↑ 6.8% |
| ៨.១៣ ឃ្លោក* | Kg | 2,000 | ● | ↓ -15.4% | → 2.1% |
| ៨.១៤ ត្រឡាច | Kg | 2,291 | ↑ 28.2% | ↓ -18.8% | ↑ 7.8% |
| ៨.១៥ ត្រប់វែង | Kg | 2,837 | ↓ -9.0% | ↓ -18.0% | ↑ 16.4% |
| ៨.១៦ ត្រប់ស្រួយ* | Kg | 2,767 | ↓ -10.6% | ↓ -21.5% | → 4.4% |
| ៨.១៧ ប៉េងប៉ោះ* | Kg | 2,810 | ↓ -23.3% | ↓ -25.8% | ↑ 6.7% |
| ៨.១៨ននោងមូល | Kg | 2,574 | ↑ 10.3% | ↓ -15.3% | ↑ 13.2% |
| ៨.១៩ ននោងជ្រុង* | Kg | 2,563 | ↑ 10.4% | ↓ -16.5% | ↑ 10.8% |
| ៨.២០ ល្ពងខ្ទី* | Kg | 1,502 | ↑ 13.3% | ↑ 32.9% | ↑ 27.5% |
| ៨.២១ សណ្តែកកួរ | Kg | 3,192 | → -0.3% | ↓ -24.6% | → 0.3% |
| ៨.២២ ត្រយូងចេក* | Kg | 1,859 | → 1.2% | → 0.1% | ↓ -9.5% |
| ៨.២៣ ផ្កាខាត់ណា* | Kg | 5,004 | → 2.1% | ↓ -31.1% | ↑ 16.8% |
| ៨.២៤ ដើមខាត់ណា* | Kg | 3,512 | ↓ -8.6% | ↓ -36.1% | ↓ -11.9% |
| ៨.២៥ ដំឡូងពណ៌លឿង* | Kg | 2,562 | → -1.4% | ↑ 35.1% | ↑ 31.2% |
| ៨.២៦ ខ្ទឹមសរ | Kg | 4,784 | → 4.4% | ↑ 5.6% | ● |
| ៨.២៧ អំពិលទុំ (មានគ្រាប់) | Kg | 3,439 | → -3.7% | ↓ -8.6% | ● |
| ៩.១ ចេកណាំវ៉ាទុំ | Kg | 1,769 | → 0.7% | ↑ 5.5% | ● |
| ៩.២ ស្វាយកែវរមៀតទុំ | Kg | 1,750 | ↓ -36.0% | → 0.0% | ● |
| ១០.១ ទឹកដោះគោស្រស់ | 140 ml | 1,394 | ↓ -6.8% | ↓ -9.9% | ● |
| ១១.១ កូកាកូឡា | 330 ml | 1,554 | → -1.5% | → -4.3% | ● |
| ៧.១ សាំងធម្មតា | litre | 4,187 | → 3.2% | → -2.1% | ● |
| ៧.២ ម៉ាស៊ូត | litre | 4,411 | → -0.2% | ↓ -10.9% | ● |
| ៨.១ ជីអ៊ុយរ៉េ | Kg | 2,790 | ↓ -8.5% | ↓ -15.5% | ● |

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្តែង ឧ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

** តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្តល់អាហារពេលព្រឹកតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។*

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

- ↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%
- → ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%
- ↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%
- ● គ្មានតម្លៃកត់ត្រា

# ឧបសម្ព័ន្ធទី៣៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

ការគណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ដែលបង្ហាញនៅក្នុងរបាយការណ៍នេះ ផ្អែកចម្បងលើការវិភាគកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា។ ដើម្បីរៀបចំកញ្ចប់អាហារសម្រាប់ការវិភាគនេះ ក្រុមគ្រួសារគោលត្រូវបានវិភាគចេញពីទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៤ ផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

i. គ្រួសារដែលមានការចំណាយប្រចាំខែនៅចន្លោះបញ្ចភាគទី២ និងទី៤

ii. គ្រួសារមានសន្តិសុខស្បៀងគ្រប់គ្រាន់ (ពិន្ទុកម្រិតទទួលទានអាហារអាចទទួលយកបាន)

iii. គ្រួសារមិនបានប្រើប្រាស់យុទ្ធសាស្ត្រអវិជ្ជមានដើម្បីដោះស្រាយបញ្ហាខ្វះស្បៀង។

កញ្ចប់ស្បៀងអាហារសម្រាប់ក្រុមគ្រួសារគោលនេះ ត្រូវបានបង្កើតឡើងដើម្បីស្វែងយល់អំពីទម្រង់នៃការទទួលទានអាហារ ដែលសមស្របទៅនឹងអាហាររបស់គ្រួសារនីមួយៗគួរទទួលទាន ដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម។[1] ដូច្នេះ ស្បៀងអាហារជាក់លាក់ត្រូវបានកំណត់ ដើម្បីជាតំណាងឱ្យក្រុមអាហារនានាដែលមាននៅក្នុងផ្នែកការចំណាយលើស្បៀងអាហារ (សូមមើលតារាងទី២សម្រាប់បញ្ជីស្បៀងអាហារពេញ)។ ថាមពលគីឡូកាឡូរី និងបរិមាណស្បៀងត្រូវបានវិភាគចេញពីទិន្នន័យការចំណាយរបស់អង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៤ ដើម្បីកំណត់កម្រិតកាឡូរីមួយកញ្ចប់សម្រាប់មនុស្សម្នាក់ គួរទទួលទានដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម តាមទម្រង់សិទ្ធិទទួលបានជាមូលដ្ឋាន។

**តារាង២៖ សង្ខេបធាតុចូលសម្រាប់គណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន**

| ក្រុមអាហារ[2] | ប្រភេទអាហារ[3] | ប្រភេទអាហារ[4] | គីឡូកាឡូរី/ម្នាក់/ថ្ងៃ[2] | ក្រាម/ម្នាក់/ថ្ងៃ[2] | រៀល/ក្រាម[4] | រៀល/ម្នាក់/ខែ[4] |
|---|---|---|---|---|---|---|
| Cereals | Rice | 1.1. អង្ករចម្រុះ/ Mixed Rice | 1,470.23 | 413.0 | 2.1 | 26,838 |
| Fish | Mud fish | 2.1. ត្រីផ្ទក់(រស់)/ Snakehead fish (Live) | 76.47 | 91.0 | 11.1 | 30,752 |
| Meat | Pork | 3.1. សាច់ជ្រូកពជាន់/ 3-layer pork/Pork with fat | 77.75 | 40.7 | 16.0 | 19,851 |
| Egg | Duck egg | 4.1. ស៊ុតទា/Duck egg | 21.92 | 11.8 | 8.8 | 3,181 |
| Diary | Milk | ---NA--- | 7 | 12.0 | --- | --- |
| Oil | Vegetable oil | 5.1. ប្រេងឆា/ Vegetable Oil: Saji ឬ Mongsay ឬ Cailan | 115.36 | 12.8 | 6.5 | 2,522 |
| Veg | Morning Glory | 8.1. ត្រកួន/ Morning glory | 34.76 | 231.7 | 3.2 | 22,578 |
| Tuber | Sweet Potato | 8.25. ដំឡូងផ្ទាពណ៌លឿង/ Orange-flesh Sweet Potatoes | 19.21 | 19.6 | 3.2 | 1,889 |
| Pulses | Soybean/green bean | ---NA--- | 8 | 21.6 | --- | --- |
| Fruit | Banana | ---NA--- | 91 | 96.4 | --- | --- |
| | | **Total** | **1,937** | **950.6** | **---** | **107,610** |

ប្រភេទស្បៀងអាហារមួយចំនួនមិនត្រូវបានតាមដានដោយប្រព័ន្ធតាមដានទីផ្សាររបស់ WFP ដូច្នេះប្រភេទស្បៀងអាហារជាក់លាក់នោះមិនត្រូវបានរាប់បញ្ចូលនៅក្នុងកញ្ចប់ស្បៀងអាហារ ដែលបានតាមដាននៅក្នុងរបាយការណ៍នេះទេ។ ទោះជាយ៉ាងណា ទម្រង់នៃការបរិភោគស្បៀងអាហារនីមួយៗ (ទម្ងន់ គិតជា ក្រាម/ម្នាក់/ថ្ងៃ) អាចតំណាងឱ្យតម្លៃនៃម្ហូបអាហារប្រកបដោយអាហារូបត្ថម្ភ នៅក្នុងប្រទេសកម្ពុជា។

*[1] តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាននៅក្នុងរបាយការណ៍បច្ចុប្បន្នភាពទីផ្សារនេះ មិនដូចគ្នា ជាមួយតម្លៃនៃកញ្ចប់ស្បៀងអាហាររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការប្រើសម្រាប់គណនាបន្ទាត់ភាពក្រីក្រថ្នាក់ជាតិឡើង។ កញ្ចប់ស្បៀងអាហារនៅក្នុងរបាយការណ៍នេះត្រូវបានគណនាដោយប្រើវិធីសាស្ត្រផ្សេង ហើយមានប្រយោជន៍ជាចម្បងសម្រាប់តម្លៃស្បៀងអាហារ។*

*[2] ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៤ វិទ្យាស្ថានជាតិស្ថិតិ ប្រទេសកម្ពុជា។*

*[3] ការប៉ាន់ប្រមាណពីគម្លាតនៃការចំណាយ និងកញ្ចប់ចំណាយអប្បបរមានៅកម្ពុជា។ របាយការណ៍បច្ចេកទេស ខែមិថុនាឆ្នាំ២០២០ WFP ប្រចាំប្រទេសកម្ពុជា។*

*[4] បច្ចុប្បន្នភាពទីផ្សារ ខែកុម្ភៈ ឆ្នាំ២០២៣ WFP ប្រចាំប្រទេសកម្ពុជា។*